THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**William R. Hite, Jr., Ed.D.**
Superintendent

ថ្ងៃទី 22 ខែកុម្ភៈ ឆ្នាំ 2021

សួស្តីគ្រួសារនៃមណ្ឌលសាលា Philadelphia ជាទីមេត្រី!

ខ្ញុំចង់ផ្តល់ព័ត៌មានថ្មីជូនអ្នកអំពីមូលហេតុដែលខ្ញុំបន្តជឿជាក់ថា យើងបានត្រៀមរួចជាស្រេច ក្នុងការចាប់ផ្តើមបើកទ្វារសាលារៀនរបស់យើងឡើងវិញ សម្រាប់ការសិក្សាដោយផ្ទាល់ ដែលចាប់ផ្តើមនៅថ្ងៃទី 1 ខែមីនា ជាមួយសិស្ស PreK-2 ដែលគ្រួសារសិស្សបានជ្រើសយកការសិក្សាតាមប្រព័ន្ធកូនកាត់។

ដូចដែលខ្ញុំជូនដំណឹងពីមុនរួចហើយ យើងបានធ្វើការយ៉ាងជិតស្និតជាមួយនឹងមន្ទីរពេទ្យកុមារ Philadelphia (Children's Hospital of Philadelphia (CHOP (CHOP)) និងនាយកដ្ឋានសុខភាពសាធារណៈ Philadelphia ក្នុងការរៀបចំវិធីសាស្ត្រច្រើនស្រទាប់ ដើម្បីការពារគ្រប់គ្នា ដែលចូលក្នុងសាលារៀនរបស់យើង។ ផែនការរបស់យើង រួមមាន៖

1. ការធ្វើតេស្តឆាប់រហ័សសម្រាប់សិស្ស – រៀងរាល់សប្តាហ៍ គិលានុបដ្ឋាកសាលារៀននឹងធ្វើតេស្តឆាប់រហ័សលើសិស្សចំនួន 20% នៃសិស្សទាំងអស់ ដែលសិក្សាដោយផ្ទាល់ ក៏ដូចជា សិស្សដែលមិនអាចពាក់ម៉ាស់ ឬមិនអាចរក្សាគម្លាតសុវត្ថិភាពបាន ដោយសារស្ថានភាពសុខភាព ឬពិការភាព។ សិស្សដែលមានរោគសញ្ញាដូចជំងឺកូវីដ ក្នុងអំឡុងពេលសិក្សានៅសាលារៀន នឹងត្រូវធ្វើតេស្តភ្លាមៗ។ សូមសិក្សាបន្ថែមអំពីផែនការធ្វើតេស្តសិស្សរបស់យើងនៅ philasd.org/studenthealth/covidtesting។

2. ការធ្វើតេស្តឆាប់រហ័សលើបុគ្គលិក – បុគ្គលិកនៅសាលារៀនទាំងអស់នឹងត្រូវទទួលការធ្វើតេស្តជំងឺកូវីដរៀងរាល់សប្តាហ៍ចំនួនមួយដងក្នុងមួយសប្តាហ៍ នៅពេលការសិក្សាដោយផ្ទាល់ចាប់ផ្តើមដំណើរការ។

3. ការចាក់ថ្នាំវ៉ាក់សាំងជំងឺកូវីដ-19 សម្រាប់បុគ្គលិក – ដោយទទួលបានជំនួយពី CHOP យើងបានធ្វើការណាត់ជួបរួចហើយសម្រាប់បុគ្គលិកដែលជួបសិស្ស ដែលជ្រើសរើសទទួលថ្នាំវ៉ាក់សាំង ហើយការចាក់ថ្នាំវ៉ាក់សាំងចាប់ផ្តើមនៅថ្ងៃនេះ។

4. ស្រទាប់សុវត្ថិភាពផ្សេងទៀត - បុគ្គលិក និងសិស្សទាំងអស់ត្រូវពាក់ម៉ាស់ ឬរបាំងមុខផ្សេងទៀត ដែលនឹងត្រូវផ្តល់ជូនពួកគេ។ ការរៀបចំថ្នាក់រៀនថ្មី និងស្លាកសញ្ញា នឹងជម្រុញការរក្សា

គម្លាតសុវត្ថិភាព។ ហើយក៏មានទីតាំងលាងដៃ ដែលមិនចាំបាច់ប៉ះផ្ទាល់ ទីតាំងផ្គត់ផ្គង់សម្ភារសម្អាត ស្លាកសញ្ញាបង្ហាញពីចំនួនសិស្សអតិបរមាក្នុងថ្នាក់រៀន និងពិធីសារស្តីពីការបង្កើនការសម្អាតផងដែរ។

5. ខ្សែទូរស័ព្ទបន្ទាន់ – មាតាបិតា ដែលមានសំណួរ អាចទាក់ទងមកយើងបាន ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពីម៉ោង 8 a.m. - 4:30 p.m. តាមលេខ 215-400-5300 (ភាសាអង់គ្លេស) ឬស្វែងរកភាសាផ្សេងទៀត ត្រង់នេះ។ និង

6. ការបង្ហាញទីតាំង – អាចមកទស្សនាទីតាំងបាន តាមការស្នើសុំ ចំពោះទីតាំងសាលារៀនទាំងអស់ ដែលយើងគ្រោងនឹងបើកទ្វារឡើងវិញ។ គ្រាន់តែទាក់ទងសាលារៀនកូនរបស់អ្នក ដើម្បីទទួលបានព័ត៌មានលម្អិត។

សប្តាហ៍មុន វេជ្ជបណ្ឌិត Dr. David Rubin ប្រធានមន្ទីរ Policy Lab របស់ CHOP បានផ្តល់ចម្លើយនៅក្នុងសវនាការរបស់ក្រុមប្រឹក្សាទីក្រុងអំពី វិទ្យាសាស្ត្រនៃជំងឺកូវីដ & ការសិក្សាដោយផ្ទាល់ , គោលការណ៍ណែនាំថ្មីរបស់ CDC សម្រាប់ការបើកសាលារៀនឡើងវិញ, ប្រព័ន្ធខ្យល់ចេញចូល និងប្រធានបទច្រើនថែមទៀត។ គាត់បានបញ្ជាក់ថា៖ "អ្វីទាំងអស់ដែលបានលើកឡើង ដោយគិតពីអត្រាចម្លងធ្លាក់ចុះ ផែនការសុវត្ថិភាពរឹងមាំ និងការដាក់បន្ថែមនូវកម្មវិធីធ្វើតេស្តធានាដែលរឹងមាំ យើងបានធ្វើសេចក្តីសន្និដ្ឋានថា មានឱកាសបើកចំហរសម្រាប់ការបញ្ជូនសិស្សបន្ថែមមកថ្នាក់រៀនវិញ ...."។

វិទ្យាសាស្ត្រគឺមានភាពច្បាស់លាស់។ យើងអាចបើកសាលារៀនយើងឡើងវិញបានប្រកបដោយសុវត្ថិភាព ដោយអនុវត្តតាមការនាំមុខរបស់មណ្ឌលសាលាធំៗជាច្រើននៅក្នុងប្រទេស។ យើងនឹងបន្តស្វែងរកចំណុចរួមនៅក្នុងដំណើរការសម្របសម្រួលឆ្ពោះទៅគោលដៅនេះ។

ដោយសេចក្តីរ៉ាប់អាន!

William R. Hite Jr., Ed.D.
នាយក
មណ្ឌលសាលា Philadelphia